សុន្ទរកថារបស់ **ឯកឧត្តម លោក គូរ៉ូត ម៉ាសាហ៊ីមី**

ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៤ តុលា ២០១២

**សូមគោរព ឯកឧត្តម ពេជ្រ វាសនា នាយកមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ និងឧតុនិយម!**
**សូមគោរព លោក ជុំ សុភី ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមខេត្តព្រៃវែង!**
**សូមគោរព អស់លោក លោកស្រី!**

ជាបឋម ខ្ញុំសូមសំដែងនូវមរណៈទុក្ខដ៏ក្រៀមក្រំជាមួយព្រះញាតិវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រកម្ពុជាចំពោះការយាងចូលព្រះទីវង្គតនៃ ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបិតាឯករាជ្យជាតិខ្មែរ។

ថ្ងៃនេះ យើងបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងសម្រាប់គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រទំនប់ព្រៃគ្រើលក្នុងខេត្តព្រៃវែង។

ការអភិវឌ្ឍវិស័យកសិកម្ម ពិសេសការបង្កើនផលិតកម្មស្រូវ គឺជាវិស័យអាទិភាពខ្ពស់បំផុតមួយក្នុងចំណោមវិស័យអាទិភាពជាគោលដៅដទៃទៀតដើម្បីអភិវឌ្ឍប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាលបាននិងកំពុងពង្រីក និងជួសជុលប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេសយ៉ាងសកម្មដើម្បីជំរុញផលិតកម្មស្រូវ ដើម្បីអាចជួយបង្កើនប្រាក់ចំណូលរបស់កសិករ និងកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការអភិវឌ្ឍ និងកែលម្អប្រព័ន្ធធារាសាស្ត្រ ក៏ដូចជាការផ្ទេរបច្ចេកវិជ្ជាក្នុងការដាំដុះ។

ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៩៧,៥៩៦ ដុល្លាអាមេរិក នៅថ្ងៃនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ជួសជុលទំនប់អាងស្តុកទឹកប្រវែង២,១០០ម៉ែត្រ និងសំណង់លូដែលមានស្រាប់ ព្រមទាំងសាងសង់បន្ថែមនូវសំណង់លូ និងទ្វារទឹកដទៃទៀត។ យើងរំពឹងថា គម្រោងនេះនឹងជួយធ្វើឲ្យកាន់តែប្រសើរឡើងនូវការទទួលបានទឹកស្រោចស្រពរបស់ប្រជាកសិករប្រមាណ១,២៧៥គ្រួសារនៅក្នុងតំបន់ ក៏ដូចជាជួយបង្កើនផលិតកម្មស្រូវ និងកាត់បន្ថយភាពក្រីក្ររបស់ពួកគេផងដែរ។

ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន ហើយទំនប់ប្រឡាយ និងសំណង់ដែលបានជួសជុលហើយនោះនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!